ស្វែងយល់បន្ថែមអំពីការលូតលាស់កូនរបស់អ្នក៖

# ការពិនិត្យតាមដាន និងការត្រួតពិនិត្យលើការលូតលាស់



ព្រឹត្តិការណ៍សំខាន់ៗក្នុងការលូតលាស់ (របៀបដែលកុមារលេង រៀន និយាយ ធ្វើសកម្មភាព ឬបញ្ចេញចលនា) គឺជាសកម្មភាពដែលកុមារភាគច្រើនអាចធ្វើបាននៅអាយុជាក់លាក់ណាមួយ។ កុមារតូចៗទាំងអស់ត្រូវការទាំងការតាមដានការលូតលាស់ និងការពិនិត្យមើលការលូតលាស់ ដើម្បីជួយអ្នក និងវេជ្ជបណ្ឌិតរបស់កូនអ្នក លោកគ្រូអ្នកគ្រូ និងអ្នកផ្តល់សេវាផ្សេងទៀត ដឹងថាតើការលូតលាស់របស់កូនអ្នកកំពុងវិវឌ្ឍតាមគន្លងឬអត់។

## ការពិនិត្យតាមដានការលូតលាស់

| | |
|---|---|
| **នរណាខ្លះ៖** | អ្នក — មាតាបិតា ជីដូនជីតា អ្នកមើលថែផ្សេងទៀត |
| **អ្វីខ្លះ៖** | ស្វែងរកព្រឹត្តិការណ៍សំខាន់នៃការលូតលាស់ |
| **ពេលណា៖** | ពីកើតរហូតដល់ 5 ឆ្នាំ។ |
| **មូលហេតុ៖** | ដើម្បីជួយអ្នកឱ្យ៖ |

- តាមដានការលូតលាស់របស់ កូនអ្នក
- ពិគ្រោះអំពីការលូតលាស់របស់កូនអ្នក ជាមួយ វេជ្ជបណ្ឌិត និងអ្នកផ្តល់សេវា ថែទាំកុមារ
- ស្វែងយល់អ្វីដែលរំពឹងថាកើតឡើងបន្ទាប់
- កំណត់រកក្តីបារម្ភណាមួយឱ្យបានឆាប់

## ការត្រួតពិនិត្យលើការលូតលាស់

| | |
|---|---|
| **នរណាខ្លះ៖** | អ្នកផ្តល់សេវាថែទាំសុខភាព គ្រូបង្រៀនទៀត កុមារតូច ឬអ្នកផ្តល់សេវាបណ្តុះបណ្តាលផ្សេង |
| **អ្វីខ្លះ៖** | ស្វែងរកព្រឹត្តិការណ៍សំខាន់ៗនៃការលូតលាស់ |
| **ពេលណា៖** | **ការត្រួតពិនិត្យលើការលូតលាស់**នៅអាយុ 9, 18, និង 30 ខែ<br>**ការត្រួតពិនិត្យជំងឺអូទីហ្សឹម**នៅអាយុ 18 និង 24 ខែ |
| **មូលហេតុ៖** | ដើម្បីស្វែងយល់៖ |

- ប្រសិនបើកូនរបស់អ្នកត្រូវការជំនួយបន្ថែមសម្រាប់ការលូតលាស់ ព្រោះវាមិនតែងតែអាចកត់សម្គាល់បានសម្រាប់ វេជ្ជបណ្ឌិត អ្នកផ្តល់សេវាថែទាំ កុមារ ឬមាតាបិតា នោះទេ
- ប្រសិនបើការវាយតម្លៃលើការលូតលាស់បន្ថែមទៀត ត្រូវបានណែនាំឱ្យធ្វើបែបនេះ

**វិធី៖** តាមរយៈការប្រើឧបករណ៍ត្រួតពិនិត្យផ្លូវការ និងមានការបញ្ជាក់ត្រឹមត្រូវ – ស្វែងយល់បន្ថែមតាមរយៈគេហទំព័រ **www.hhs.gov/WatchMeThrive**

- **កុមារតូចៗទាំងអស់ត្រូវការទាំងការតាមដានការលូតលាស់ និងការត្រួតពិនិត្យមើលកាលូតលាស់។**
- **បុគ្គលដែលស័ក្តិសមបំផុតក្នុងការតាមដានដំណើរការលូតលាស់របស់កូនអ្នកគឺជារូបអ្នក!**
  ចែករំលែកបញ្ជីត្រួតពិនិត្យព្រឹត្តិការណ៍សំខាន់ៗរបស់**កូនអ្នក** និងព័ត៌មានពាក់ព័ន្ធណាមួយពីលោកគ្រូអ្នកគ្រូរបស់កូនអ្នក ឬអ្នកផ្តល់សេវាផ្សេងទៀតជាមួយ វេជ្ជបណ្ឌិតរាល់ពេលទៅជួបពិគ្រោះកុមារសុខភាពល្អ។ បំពេញបញ្ជីត្រួតពិនិត្យព្រឹត្តិការណ៍សំខាន់ៗដោយប្រើ កម្មវិធី ***Milestone Tracker*** របស់ CDC ឥតគិតថ្លៃពី App Store ឬ Google Play
- **ចុះបើកូនរបស់អ្នកមិនវិវឌ្ឍដល់ព្រឹត្តិការណ៍សំខាន់ៗដូចការរំពឹងទុកវិញ?**
  អ្នកស្គាល់កូនរបស់អ្នកជាងអ្នកណាៗទាំងអស់។ ប្រសិនបើអ្នកព្រួយបារម្ភអំពីការលូតលាស់របស់កូនអ្នក សូមពិភាក្សាជាមួយវេជ្ជបណ្ឌិតរបស់កូនអ្នកអំពី ក្តីកង្វល់របស់អ្នក ហើយសាកសួរអំពីការត្រួតពិនិត្យលើការលូតលាស់។ កុំរង់ចាំ! ការធ្វើសកម្មភាពទាន់ពេលអាចធ្វើឱ្យមានភាពខុសគ្នាពិតប្រាកដ។

**ការលូតលាស់របស់កូនអ្នកគឺជាដំណើរមួយ។ ការពិនិត្យតាមដាន និងការត្រួតពិនិត្យនេះនឹងបង្ហាញផ្លូវដល់អ្នក។**

[ឯកសារ"សិក្សាពីសញ្ញា។ ធ្វើសកម្មភាពទាន់ពេល។" (ឧ. "ខ្លឹមសារដែលបានផ្តល់ (ជាភាសាអង់គ្លេស) ដោយកម្មវិធីសិក្សាពីសញ្ញា ធ្វើសកម្មភាពទាន់ពេល។ នៃមជ្ឈមណ្ឌលសម្រាប់ទប់ស្កាត់ និងការពារជំងឺ។ www.cdc.gov/ActEarly។ ការបកប្រែខ្លឹមសារដែលផ្តល់ជូនដោយ L.A. Care Health Plan។"]

**ប្រសិនបើអ្នកចង់ដឹងបន្ថែម សូមសាកសួរវេជ្ជបណ្ឌិតរបស់អ្នក។**

Help Me Grow LA is a collaboration between